ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន

លេខ: ៦៤ អរម

រាជធានីភ្នំពេញ . ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០៩

ខុទ្ទកាល័យឯកឧត្តម ស ខេង
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ចូល
លេខ: 212
ថ្ងៃ: 19/09/ឆ្នាំ08
ម៉ោង:............ម៉ោង.....

**សូមគោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**តាមរយៈ : ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** : សំណើសុំគោលការណ៍ ដើម្បីធ្វើការផ្លាស់ប្តូរឈ្មោះស្រុក ខណ្ឌ គោលដៅនៃគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការប្រគល់ភារកិច្ចក្នុងការរៀបចំកិច្ចលទ្ធកម្មសំណង់អាគារការិយាល័យច្រកចេញចូលតែមួយទៅឱ្យគណៈកម្មាធិការប្រតិបត្តិខេត្ត ។

**យោង** : - លិខិតលេខ៦៧២១ សហវ-វស ចុះថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ២០០៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- លិខិតលេខ១២រប.កគស ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ២០០៨ របស់ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ និងចំណោរឯកភាព របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.វ.វ ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ២០០៨។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជំរាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា:ក្នុងឆ្នាំទី១ នៃការអនុវត្តគម្រោងការិយាល័យច្រកចេញចូលតែមួយ ក្រសួងមហាផ្ទៃ និងធនាគារពិភពលោកបានឯកភាពជ្រើសរើសយកស្រុក ខណ្ឌគោលដៅចំនួន០៧រូមមាន : **ស្រុកតាខ្មៅ** ខេត្តកណ្តាល **ស្រុកត្បូងឃ្មុំ** ខេត្តកំពង់ចាម **ស្រុកក្រចេះ** ខេត្តក្រចេះ **ស្រុកស្ទឹងសែន** ខេត្តកំពង់ធំ **ស្រុកអូរជ្រៅ** ខេត្តបន្ទាយមានជ័យ **ស្រុកពាមរក៍** ខេត្តព្រៃវែង **និងខណ្ឌមិត្តភាព** ក្រុងព្រះសីហនុ។ បច្ចុប្បន្នស្ថានភាពស្រុក ខណ្ឌគោលដៅខាងលើនេះ ត្រូវបានផ្លាស់ប្តូរតាមស្មារតីនៃអនុក្រឹត្យរបស់រាជរដ្ឋាភិបាល មកជា :

- ស្រុកតាខ្មៅ ទៅជា ក្រុងតាខ្មៅ
- ស្រុកស្ទឹងសែន ទៅជា ក្រុងស្ទឹងសែន
- ស្រុកក្រចេះ ទៅជា ស្រុកចិត្របុរី និងបង្កើតក្រុងក្រចេះ
- ខណ្ឌមិត្តភាព មកជា ក្រុងព្រះសីហនុ
- បង្កើតក្រុងប៉ោយប៉ែត ដោយកាត់យកឃុំប៉ោយប៉ែត និងឃុំនិមិត្ត ពីស្រុកអូរជ្រៅ
- បង្កើតក្រុងសួង ដោយកាត់យកឃុំសួង និង ឃុំវិហារលួង ពីស្រុកត្បូងឃ្មុំ

ដោយផ្អែកទៅលើស្ថានភាពជាក់ស្តែងនៃការផ្លាស់ប្តូរស្រុក ខណ្ឌគោលដៅខាងលើនេះ និងដោយផ្អែកទៅលើគោលការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់សិទ្ធិឱ្យក្រសួង ស្ថាប័នជាភ្នាក់ងារអនុវត្តគម្រោង ជាអ្នករៀបចំកិច្ចលទ្ធកម្មលើគម្រោងដែលទាក់ទិននិងកិច្ចលទ្ធកម្មសំណង់ដែលមានតម្លៃក្រោម ១០០.០០០ ដុល្លាអាមេរិក ខ្ញុំបាទសូមគោរពសុំអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់នូវកិច្ចការមួយចំនួនដូចខាងក្រោម :

១- ជ្រើសរើសយកក្រុង ស្រុកគោលដៅ សម្រាប់អនុវត្តឆ្នាំទី១ រួមមាន : **ក្រុងតាខ្មៅ** ខេត្តកណ្តាល **ក្រុងស្ទឹងសែន** ខេត្តកំពង់ធំ **ក្រុងក្រចេះ** ខេត្តក្រចេះ **ក្រុងព្រះសីហនុ** ខេត្តព្រះសីហនុ **ក្រុងប៉ោយប៉ែត** ខេត្តបន្ទាយមានជ័យ **ក្រុងសួង** ខេត្តកំពង់ចាម **និងស្រុកពាមរក៍** ខេត្តព្រៃវែង ។

២- គំនូសប្លង់អគារការិយាល័យច្រកចេញចូលតែមួយ ( ដូចប្លង់ជូនភ្ជាប់មកជាមួយ )

៣- ផ្តល់សិទ្ធិឱ្យគណៈកម្មាធិការប្រតិបត្តិខេត្តសាមីនីមួយៗ ជាអ្នករៀបចំធ្វើកិច្ចលទ្ធកម្មសំណង់អគារការិយាល័យច្រកចេញចូលតែមួយ ។

៤- ធ្វើលិខិតស្នើសុំការឯកភាពពីធនាគារពិភពលោកលើចំនុចទាំងបីខាងលើ ។

អាស្រ័យហេតុនេះ សូមឯកឧត្តម មេត្តាពិនិត្យ និងសំរេចជាគោលការណ៍ និងមានមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់

**អគ្គនាយក និងជា**

**ប្រធានក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ**

លេង_វី

សត់_សេដ្ឋា